*បកប្រែក្រៅផ្លូវការ*
*Unofficial Translation*

*<u>ហាមឃាត់ផ្សព្វផ្សាយរហូតដល់ ថ្ងៃទី៦ ខែមេសា ឆ្នាំ២០១១ ម៉ោង០៤:០០ ម៉ោងនៅទីក្រុងហ្សឺណែវ និងម៉ោង ០៩:០០ ក្រុងបាងកកនិងភ្នំពេញ</u>*

<u>សម្ព័ន្ធភាពអង្គការប្រឆាំងគ្រាប់ចង្កោម(CMC) ថ្កោលទោសថៃក្នុងការប្រើប្រាស់គ្រាប់បែកចង្កោមនៅក្នុងទឹកដីកម្ពុជា</u>

*ថៃ និង កម្ពុជាគួរចូលរួមក្នុងសន្ធិសញ្ញាពិភពលោកក្នុងការហាមឃាត់ការប្រើប្រាស់គ្រាប់បែកចង្កោម*

(ថ្ងៃទី៦ ខែមេសា ឆ្នាំ ២០១១ ក្រុងបាងកក/ក្រុងហ្សឺណែវ/ក្រុងភ្នំពេញ)-យោងតាមការស៊ើបអង្កេតនៅលើតំបន់ពីរផ្សេងគ្នា សម្ព័ន្ធអង្គការ CMC បានសន្និដានថា ថៃបានប្រើប្រាស់គ្រាប់បែកចង្កោមមកលើទឹកដីកម្ពុជានៅក្នុងកំឡុងពេលមានជម្លោះព្រំដែនកាលពីខែកុម្ភៈឆ្នាំ២០១១កន្លងមក។ នៅក្នុងកិច្ចប្រជុំជាមួយសម្ព័ន្ធអង្គការ CMCកាលពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០១១ មន្ត្រីថៃបានអះអាងបញ្ជាក់ពីការប្រើប្រាស់គ្រាប់បែកចង្កោម។

នេះជាការប្រើគ្រាប់បែកចង្កោមលើកទី១ នៅលើពិភពលោកចាប់តាំងពីមានអនុសញ្ញាប្រឆាំងគ្រាប់បែកចង្កោមនាឆ្នាំ ២០០៨ ចូលជាធរមាននិងក្លាយជាច្បាប់អន្តរជាតិនោះ។ សម្ព័ន្ធអង្គការ CMC សូមធ្វើការថ្កោលទោសការប្រើប្រាស់គ្រាប់បែកចង្កោមណាមួយ ហើយអំពាវនាវយ៉ាងទទូចឲ្យប្រទេសថៃ និង កម្ពុជាប្តេជ្ញាឈប់ប្រើជាបន្ទាន់ និងទទួលយកនូវសន្ធិសញ្ញាពិភពលោកស្តីអំពីការហាមប្រាមប្រើប្រាស់សព្វាវុធ។

ឡូរ៉ា ឈីមែន (Laura Cheeseman) នាយកសម្ព័ន្ធអង្គការ CMC បានថ្លែងថា «វាគួរព្រួយបារម្ភណាស់ដែលប្រទេសណាមួយបែរមកប្រើគ្រាប់បែកចង្កោមដែលត្រូវបានហាមឃាត់និងប្រឆាំងដោយសហគមន៍អន្តរជាតិនោះ »។ «ប្រទេសថៃជាប្រទេសឈានមុខមួយក្នុងការប្រឆាំងរាល់ទម្រង់នៃការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ហើយគួរឲ្យភ្ញាក់ផ្អើលដែលប្រទេសនេះបានយកអាវុធគេហាមឃាត់មកប្រើសម្លាប់មនុស្សដោយគ្មានរើសមុខ ក៏ដូចជាធ្វើឲ្យជនស៊ីវិលរងរបួសក្នុងលក្ខណៈនេះផងដែរ»។

នៅក្នុងកិច្ចប្រជុំកាលពីថ្ងៃទី៥ ខែមេសា ឯកអគ្គរាជទូតថៃប្រចាំអង្គការសហប្រជាជាតិនៅទីក្រុហ្សឺណែវបានអះអាងថា ថៃបានប្រើគ្រាប់កាំភ្លើងធំធុនDPICM ១៥៥មមក្នុងបំណងបញ្ជូនគ្រាប់បែកចង្កោមក្នុងកិច្ចអន្តរាគមន៍។ លោកឯកអគ្គរាជទូតថៃបានបន្តថា ថៃប្រើគ្រាប់បែកចង្កោម«ក្នុងកិច្ចស្វ័យការពារខ្លួន»ដោយប្រើគោលការណ៍ស្តីពី «ភាពចាំបាច់សមស្រប និង អនុវត្តតាមក្រមប្រតិបត្តិយោធាផងដែរ»។ គាត់បាន

ចោទប្រកាន់កងទ័ពកម្ពុជាពីការប្រើគ្រាប់រ៉ូកែតដ៏ច្រើនប្រឆាំងលើគោលដៅជាជនស៊ីវិលនៅក្នុងសាត់ទិសុក នៅក្នុងស្រុកគោកខាន់ ប្រទេសថៃ។

នៅក្នុងខែកុម្ភៈ និង ខែមេសា ឆ្នាំនេះ សមាជិកសម្ព័ន្ធអង្គការ CMC បានធ្វើបេសកកម្មដាច់ដោយឡែកពីរ ទៅកាន់តំបន់ដែលប៉ះពាល់ដោយសារគ្រាប់បែកចង្កោមនៅក្នុងប្រទេសកម្ពុជា រួមមានភូមិស្វាយជ្រុំ ភូមិសែនជ័យ និង កូនភ្នំនៅជុំវិញប្រាសាទព្រះវិហារ បានឃើញដោយផ្ទាល់ភ្នែកនូវគ្រាប់មិនទាន់ផ្ទុះតូចៗ និងសំណល់គ្រាប់បែកតូចៗដែលបណ្ដាលមកពីគ្រាប់បែកចង្កោមក្នុងទឹកដីកម្ពុជា។ អង្គការជំនួយប្រជាជនណ័រវេ (Norwegian People's Aid: NPA) បានអះអាងថា គ្រាប់មិនទាន់ផ្ទុះដែលបានរកឃើញ ជាប្រភេទគ្រាប់ធុនM42/M46 និងM85 នៃប្រភេទគ្រាប់បែកចង្កោម DPICM។

Atle Karlsen **ពីអង្គការ** NPA មានប្រសាសន៍ថា «មានប្រជាពលរដ្ឋប្រហែល ៥០០០នាក់ ដែលរស់នៅក្នុងភូមិសែនជ័យ ប្រឈមនឹងហានិភ័យពីគ្រាប់មិនទាន់ផ្ទុះទាំងនេះ។ ប្រទេសថៃត្រូវតែផ្ដល់ព័ត៌មានដល់កម្ពុជាដើម្បីជួយដល់ការបោសសម្អាតក្នុងតំបន់ដែលប៉ះពាល់ និងធ្វើឲ្យមានសុវត្ថិភាពសម្រាប់ការវិលត្រឡប់ទៅភូមិកររបស់ប្រជាជនវិញ»។

បងស្រី **ឌេននីស កូកឡិន** (Sister Denise Coghlan) ជាអ្នកដឹកនាំសម្ព័ន្ធអង្គការ CMC នៅកម្ពុជា ដែលបានចូលរួមនៅក្នុងបេសកកម្មស្រាវជ្រាវលើកទី១បានថ្លែងថា «គ្រាប់បែកចង្កោមទាំងនេះបានឆក់យកជីវិតបុរសពីរនាក់ ពីរនាក់ផ្សេងទៀតបានបាត់បង់ដៃរបស់គេ ហើយប្រាំនាក់ផ្សេងទៀតបានរងរបួស។ តំបន់នេះត្រូវតែបោសសម្អាតជាបន្ទាន់ដើម្បីបង្ការកុំឲ្យមានការឈឺចាប់ច្រើនតទៅទៀត។ កម្ពុជាត្រូវតែខិតខំធ្វើសព្វបែបយ៉ាងដើម្បីធានាសុវត្ថិភាពដល់ប្រជាជនស៊ីវិល»។

សម្ព័ន្ធអង្គការ CMC បានជម្រុញប្រទេសថៃឲ្យផ្ដល់ព័ត៌មានលំអិតស្ដីអំពីលទ្ធផលនៃការអង្កេតរបស់ខ្លួន រួមទាំងទីតាំងទាំងអស់នៃការបាញ់ផ្លោងគ្រាប់បែកចង្កោម ដើម្បីឲ្យជនស៊ីវិលបានទទួលព័ត៌មានពីការព្រមានពេញលេញអំពីគ្រោះថ្នាក់ ហើយក៏ជួយសម្រួលដល់ការបោសសម្អាតសំណល់គ្រាប់បែកតូចៗដែលបង្កគ្រោះថ្នាក់ដូចគ្រាប់មីន ប្រកបដោយប្រសិទ្ធិភាព និងប្រសិទ្ធិផលផងដែរ។ សម្ព័ន្ធអង្គការ CMC ក៏បានអំពាវនាវដល់កម្ពុជាឲ្យចូលរួមក្នុងអនុសញ្ញាស្ដីពីការប្រឆាំងគ្រាប់បែកចង្កោម ហើយជាជំហានដំបូង កម្ពុជាត្រូវប្ដេជ្ញាចិត្តមិនប្រើប្រាស់គ្រាប់ទាំងនេះ ធ្វើការប្រកាសឲ្យគេដឹងពីប្រភេទនិងបរិមាណនៃគ្រាប់បែកចង្កោមមាននៅក្នុងឃ្លាំងរបស់ខ្លួន ហើយចាប់ផ្ដើមបំផ្លាញវាចោល។

ប្រទេសកម្ពុជា និង ថៃមិនបិតនៅក្នុងចំណោម១០៨ប្រទេសផ្សេងទៀត ដែលបានចុះហត្ថលេខាលើអនុសញ្ញាស្តីអំពីការប្រឆាំងការប្រើប្រាស់គ្រាប់បែកចង្កោមនោះទេ តែប្រទេសទាំងពីរបានចូលរួមនៅក្នុងសន្ធិសញ្ញាឆ្នាំ១៩៩៧ស្តីអំពីការហាមប្រាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស។ ប្រទេសទាំងពីរបានចូលរួមនៅក្នុង «ដំណើរការទីក្រុងអូស្លូ» ដើម្បីចរចារពីការបង្កើតអនុសញ្ញាស្តីអំពីការប្រឆាំងគ្រាប់បែកចង្កោម ហើយកាលពីខែវិច្ឆិកា ឆ្នាំ ២០១០ ក៏បានចូលរួមកិច្ចប្រជុំលើកទី១របស់រដ្ឋជាភាគីនៃអនុសញ្ញានេះដែលធ្វើឡើងនៅសាធារណរដ្ឋប្រជាមានិតឡាវនៅជិតខាងខ្លួន។

កញ្ញា Cheeseman បាននិយាយថា «ជម្លោះនេះគួរតែជម្រុញឲ្យប្រទេសទាំងពីរចាត់វិធានការជាបន្ទាន់ដើម្បីប្រកាសប្រឆាំងដាច់ខាតនូវការប្រើសព្វាវុធនេះ ហើយចូលរួមនៅក្នុងសន្ធិសញ្ញាប្រឆាំងអាវុធទាំងនេះ»។

អនុសញ្ញាប្រឆាំងគ្រាប់បែកចង្កោមបានចូលជាធរមាននិងក្លាយជាច្បាប់អន្តរជាតិ កាលពីថ្ងៃទី១សីហា ឆ្នាំ ២០១០ ដោយហាមប្រាមការប្រើប្រាស់ ការផលិត ការស្តុកទុក និង ការផ្ទេរគ្រាប់បែកចង្កោម ហើយតម្រូវឲ្យរដ្ឋនានាបំផ្លាញចោលឃ្លាំងស្តុកគ្រាប់ ធ្វើការបោសសម្អាតគ្រាប់នៅក្នុងដី ជួយដល់ជនរងគ្រោះ និង សហគមន៍នានាដែលរងការប៉ះពាល់។ ចាប់តាំងពីបើកឲ្យចុះហត្ថលេខាលើអនុសញ្ញាកាលពីខែធ្នូ ឆ្នាំ ២០០៨មក មានប្រទេសចំនួន៥៥ ក្នុងចំណោមប្រទេសចំនួន១០៨ប្រទេស ដែលបានចុះហត្ថលេខា បានផ្តល់សច្ចាប័នរួចហើយ។

**ទំនាក់ទំនង:**
**បងស្រី ខ្មៅនីស កូកឡិន**
យុទ្ធនាការកម្ពុជាដើម្បីហាមប្រាមគ្រាប់មីន និង គ្រាប់បែកចង្កោម
ទូរស័ព្ទ: +855 012 488 950

**កញ្ញា ឡូរ៉ា ឈីមែន**
សម្ព័ន្ធភាពប្រឆាំងគ្រាប់បែកចង្កោម ចក្រភពអង់គ្លេស
ទូរស័ព្ទ: +44-7515-575-175

**រូបភាពស្តីអំពីគ្រាប់បែកចង្កោមនៅក្នុងទឹកដីកម្ពុជាសូមមើលក្នុង**
© Stéphane de Greef, ការត្រួតពិនិត្យមីននិងគ្រាប់បែកចង្កោម
http://www.flickr.com/photos/clustermunitioncoalition/sets/72157626310392061/with/5592080603/

**ប្រវត្តិលំអិត**

កាលពីថ្ងៃទី៤ដល់ទី៧ ខែកុម្ភៈ ឆ្នាំ២០១១ កងទ័ពកម្ពុជានិងថៃបានប៉ះប្រយុទ្ធគ្នាក្នុងតំបន់ជម្លោះតាមបណ្តោយព្រំដែនក្បែរប្រាសាទព្រះវិហារដែលជាតំបន់បេតិកភ័ណ្ឌពិភពលោក ដែលគាំពារដោយអង្គការយូនេស្កូ។ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាដែលគាំទ្រដោយរដ្ឋាភិបាល បានរាយការណ៍កាលពីថ្ងៃទី១០ ខែកុម្ភៈ ថា គេមានភស្តុតាងដែលថា កងកម្លាំងរបស់ថៃបានបាញ់គ្រាប់បែកចង្កោមមកលើតំបន់ខ្លះនៃខេត្តព្រះវិហារ(http://www.cmac.gov.kh/tblnews.php?id=68)។

កាលពីថ្ងៃទី១២ខែកុម្ភៈ ក្រុមសមាជិកនៃសម្ព័ន្ធអង្គការ CMC បានចុះស្រាវជ្រាវនៅតាមព្រំដែនក្នុងដែនដីកម្ពុជា ដែលបានធ្វើជាសាក្សីនិងថតរូបភាពគ្រាប់បែកតូចៗដែលមិនផ្ទុះមាននៅក្នុងតំបន់ពីរគឺ ក្នុងមូលដ្ឋានយោធានិងប៉ូលីសក្នុងភូមិស្វាយជ្រុំ និងជើងភ្នំប្រាសាទព្រះវិហារ។ នៅក្នុងភូមិស្វាយជ្រុំ ក្រុមសមាជិកសម្ព័ន្ធអង្គការ CMC បានថតរូបគ្រាប់បែកចង្កោមមិនទាន់ផ្ទុះដែលបែកចំហលើដីនិងមានសំណល់គ្រាប់បែកចង្កោមមិនទាន់ផ្ទុះជាច្រើនបំណែក ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធនិងរថយន្តមួយគ្រឿងខូចខាតទាំងស្រុងដោយសារតែការផ្ទុះនៃគ្រាប់បែកចង្កោម។

គ្រាប់បែកចង្កោមមួយគ្រាប់បានផ្ទុះភ្លាមៗនៅពេលដែលប៉ូលីសម្នាក់បានចាប់កាន់វាក្រោយពីគ្រាប់នេះធ្លាក់នៅឯបន្ទាយនិងបានធ្វើឲ្យប៉ូលីសពីរនាក់ស្លាប់និងប្រាំពីរនាក់រងរបួស។ ក្រុមអ្នកស្រាវជ្រាវបានជួបសម្ភាសន៍ជាមួយនឹងជនរងគ្រោះពីរនាក់ដែលកំពុងសំរាកព្យាបាលនៅក្នុងមន្ទីរពេទ្យបង្អែកត្បែងមានជ័យខេត្តព្រះវិហារដែលពួកគេរងរបួសដៃ ខ្លួន និងក្បាលដោយសារអំបែងគ្រាប់ ក៏ដូចអ្នករងគ្រោះពីរនាក់ផ្សេងទៀតដែលក្រុមស្រាវជ្រាវបានជួបសម្ភាសន៍នៅក្នុងមន្ទីរពេទ្យខេត្តសៀមរាប ដែលពួកគេទាំងពីរនាក់បានបាត់បង់ដៃក្នុងកំឡុងពេលផ្ទុះគ្រាប់។ នៅពេលដែលយើងសួរពួកគេពីប្រភេទគ្រឿងផ្ទុះដែលពួកគេបានរងរបួសនោះ ពួកគេបានចង្អុលទៅរូបភាពមួយនៃគ្រាប់បែកចង្កោមប្រភេទ M46។

តាមការចុះវាយតម្លៃដោយឡែកមួយដែលបានធ្វើឡើងនៅថ្ងៃទី១-២ ខែមេសាឆ្នាំ២០១១ ដោយក្រុមសមាជិកសម្ព័ន្ធអង្គការ CMC Norwegian People's Aid (NPA) បានបង្ហាញថា មានតំបន់ចំនួនប្រាំដែលមានរងការប៉ះពាល់ដោយសារគ្រាប់បែកចង្កោមដែលយើងបានចុះទៅមើលគឺមាន ៖ ភូមិសែនជ័យ, តំបន់ជើងភ្នំប្រាសាទព្រះវិហារ, តំបន់ភូមិអភិវឌ្ឍថ្មីនៅពាយ័ព្យស្រអែម, តំបន់វាលស្រែក្រោយបន្ទាយទាហាន និងប៉ុស្តិ៍ ប៉ូលីសមួយនៅក្នុងភូមិស្វាយជ្រុំ។ អង្គការ NPA បានសន្និដ្ឋានថាវាជាប្រភេទគ្រាប់ M42/M46 ឬក៏ M85 មាននៅរាយពាសពេញតំបន់ទាំងនេះ។ ជាងនេះទៀតមានតំបន់រងការទម្លាក់គ្រាប់ចំនួន៧កន្លែងផ្សេងទៀត ដែលកំណត់ដោយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជាថា ជាតំបន់រងការប៉ះពាល់ដោយសារគ្រាប់បែកចង្កោម ដែលជាលទ្ធផលក្រោយការវាយប្រយុទ្ធគ្នា ប៉ុន្តែតំបន់ទាំងនោះ

អង្គការ NPA មិនអាចចូលទៅដល់ឡើយ។ មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា បានប្រមាណថា ក្នុងតំបន់រងការវាយប្រហារដោយគ្រាប់បែកចង្កោមទាំង១២កន្លែងមានទំហំប្រមាណជា៣០០គីឡូម៉ែត្រការ៉េ។

ក្រុមសមាជិកសម្ព័ន្ធអង្គការ CMC បានថតរូបគ្រាប់បែកតូចៗមិនទាន់ផ្ទុះនៅក្នុងតំបន់ដែលរងការប៉ះពាល់ http://www.flickr.com/photos/clustermunitioncoalition/sets/72157626310392061/with/5592080603/ ហើយ សម្ព័ន្ធអង្គការ CMC វិភាគនូវរូបថតទាំងនេះ និងប្រាប់ថា គ្រាប់តូចទាំងនេះគឺប្រភេទM46 ដែលស្ថិតនៅក្នុងគ្រាប់បាញ់ផ្លោងប្រភេទ NR-269 155មម។ នៅក្នុងគ្រាប់បាញ់ផ្លោងនីមួយៗមានផ្ទុកនូវគ្រាប់តូចៗចំនួន៥៦គ្រាប់ ដែលគ្រាប់តូចៗមានប្រភេទ M46 គំរូមកពីសហរដ្ឋអាមេរិក។ បន្ទាប់ពីការស៊ើបអង្កេតរបស់ក្រុមសមាជិកសម្ព័ន្ធអង្គការ CMC ខាងលើរួចមក ភាគីថៃបានទទួលស្គាល់ថាខ្លួនជាអ្នកប្រើប្រាស់នូវគ្រាប់បាញ់ផ្លោងចំងាយឆ្ងាយប្រភេទ NR-269 នេះ រួមជាមួយនឹងគ្រាប់តូចៗប្រភេទ M-46។ គ្រាប់មិនទាន់ផ្ទុះប្រភេទ M85ដែលមានមេកានិកបំផ្លាញដោយខ្លួនឯងក៏គេបានរកឃើញ នៅក្នុងវាលស្រែក្បែរបន្ទាយទាហានផងដែរ។

ប្រទេសទាំងពីរ កម្ពុជានិងថៃ មានឃ្លាំងរក្សាទុកគ្រាប់បែកចង្កោម ប៉ុន្តែពួកគេបានដឹងតិចតួចពីលក្ខណៈឬសមាសធាតុរបស់វា។ រដ្ឋាភិបាលកម្ពុជាបានអះអាងក្នុងពេលកន្លងទៅពីដំណើរការពិនិត្យឡើងវិញនូវស្ថានភាពផ្នែកសន្តិសុខនិងការពារជាតិ ដែលជាហេតុផលក្នុងការពន្យាពេលចូលរួមក្នុងអនុសញ្ញា។ ភាគីថៃ បានអះអាងពីការជាប់ពាក់ព័ន្ធនឹងការមិនមានលទ្ធភាពក្នុងការកម្ទេចចោលនូវឃ្លាំងរក្សាទុកគ្រាប់ទាំងនេះ ដែលជារនាំងមិនអាចឲ្យពួកគេចូលរួមក្នុងអនុសញ្ញាក៏ដូចជាទាក់ទងនឹងកិច្ចការសន្តិសុខផងដែរ។ ប្រទេសថៃបានប្រកាសនាឆ្នាំ២០០៨ ថា ថៃគ្មានបំណងនឹងប្រើប្រាស់អាវុធយុទ្ធភ័ណ្ឌទាំងនេះក្នុងពេលខាងមុខឡើយ។

ប្រទេសកម្ពុជានិងថៃ ជារដ្ឋភាគីនៃអនុសញ្ញាហាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សនាឆ្នាំ១៩៩៧ ហើយប្រទេសកម្ពុជាក៏នឹងរៀបចំកិច្ចប្រជុំរដ្ឋភាគីលើកទី១១សន្ធិសញ្ញាអូតាវ៉ានាខែវិច្ឆិកាឆ្នាំ២០១១ខាងមុខ។

ប្រទេសក្នុងតំបន់អាស៊ីអាគ្នេយ៍ រងការប៉ះពាល់ដោយសារគ្រាប់បែកចង្កោមយ៉ាងធ្ងន់ធ្ងរខ្លាំងជាងតំបន់ដទៃទៀត ក្រោយពីការទម្លាក់គ្រាប់នេះដ៏ច្រើនសន្ធឹកសន្ធាប់មកលើប្រទេសកម្ពុជា ឡាវ និងវៀតណាមក្នុងកំឡុងទសវត្សរ៍ទី៦០និង៧០ពីសហរដ្ឋអាមេរិក។

សម្រាប់ព័ត៌មានបន្ថែមស្តីពីគោលនយោបាយនិងការអនុវត្តគ្រាប់បែកចង្កោមសូមមើលរបាយការណ៍ត្រួតពិនិត្យគ្រាប់បែកចង្កោមប្រចាំប្រទេសកម្ពុជានិងថៃឆ្នាំ២០១០។

- Cambodia
- Thailand